**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚៚៙៙៙

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៣០.៨.អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតវិទ្យាស្ថានគ្រប់គ្រងនិងពត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញលិខិតស្នើសុំរបស់ លោក ឃី ធី ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០២
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## ស ម្រេ ច

**មាត្រា ១ :** អនុញ្ញាតអោយបង្កើត គ្រឹះស្ថានឧត្តមសិក្សាឯជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានគ្រប់គ្រង និង**

ពត៌មានវិទ្យា (Institute of Management and Informatics) ហៅកាត់ជាភាសាខ្មែរ "វគព" និងហៅកាត់ជាភាសាអង់គ្លេស "IMI" ។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំង នៅផ្លូវ អូរ ០១ សង្កាត់ ០៤ ខ័ណ្ឌ មិត្តភាព ក្រុងព្រះសីហនុ ។

**មាត្រា ២ :** វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សា យ៉ាងតិច ៤ ឆ្នាំ ។

**មាត្រា ៣ :** វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មាន :

- មហាវិទ្យាល័យ គ្រប់គ្រងនិងទេសចរណ៍
- មហាវិទ្យាល័យ សេដ្ឋកិច្ចនិងពត៌មានវិទ្យា

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេសជំនាញ ដទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍ របស់វិទ្យាស្ថាន និងមាន ក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ សំរាប់ពិនិត្យលើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** នាយកវិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មានភារកិច្ច :

- ជ្រើសរើសនិស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវ ការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា និង បានទទួលជោគជ័យក្នុងការប្រលង បញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់អោយ ដោយវិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និង កីឡា ក្នុងករណីវិទ្យាស្ថាននេះ បានបំពេញ និង អនុវត្ត តាមគោលការណ៍ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានគ្រប់គ្រង និង ពត៌មានវិទ្យា មានភារកិច្ចរៀង ៗ ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិ តាមអនុក្រឹត្យនេះ ។

**មាត្រា ៨ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង អនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ភ្នំពេញ ថ្ងៃទី០៣ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងព្រះសីហនុ

  " ដើម្បីជ្រាប "
- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ